# អំណោយទាននៃ
# ព្រះវិញ្ញាណ

ដោយសារព្រះវិញ្ញាណបរិសុទ្ធ នោះខ្ញុំបានទទួលអំណាច ដើម្បីធ្វើបន្ទាល់ពីព្រះយេស៊ូវ។(១)

សេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ បានផ្សាយមកសព្វក្នុងចិត្តរបស់ខ្ញុំ ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមកខ្ញុំ (២)

ព្រះវិញ្ញាណបរិសុទ្ធបានបើកសម្ដែងក្នុងខ្លួនខ្ញុំ ដើម្បីឲ្យខ្ញុំបានធ្វើការល្អ។ (៣)

ខ្ញុំបានធ្វើតាមរបៀបនៃសេចក្ដីស្រឡាញ់ ហើយ
ស្របតាមបំណងនៃអំណោយទានខាងឯវិញ្ញាណ :

ពាក្យសំដីនៃប្រាជ្ញាវាងវៃ ពាក្យសំដីនៃចំណេះចេះស្ទាត់ មានសេចក្ដីជំនឿ អំណោយទាន ប្រោសឲ្យជា សំដែងឫទ្ធិបារមី ចេះអធិប្បាយ ចេះសង្កេតស្គាល់អស់ទាំងវិញ្ញាណ ចេះនិយាយភាសាដទៃ ចេះបកប្រែភាសាដទៃ ទាំងអស់នេះគឺជាព្រះវិញ្ញាណតែមួយដដែលនោះឯង ដែលធ្វើគ្រប់ការទាំងនោះ ទាំងចែកដល់គ្រប់គ្នាដោយមុខៗផង តាមដែលទ្រង់សព្វព្រះហឫទ័យ។ (៤)

ខ្ញុំនឹងរក្សាបញ្ញើល្អដែលផ្ញើទុកនឹងខ្ញុំ ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលសណ្ឋិតនៅក្នុងខ្ញុំ។(៥)

**អាម៉ែន!**

(១) កិច្ចការ ១:៨
(២) រ៉ូម ៥:៥
(៣) ១កូរិនថូស ១២:៧
(៤) ១កូរិនថូស ១២:៨-១១
(៥) ២ធីម៉ូថេ ១:១៤

**កិច្ចការ ១: ៨** ប៉ុន្តែ កាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនិងធ្វើជាទីបន្ទាល់ពីខ្ញុំនៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា និងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង។

**រ៉ូម ៥: ៥** ឯសេចក្តីសង្ឃឹមក៏មិនដែលនាំឲ្យយើងមានសេចក្តីខ្មាសឡើយ ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះ បានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមកយើងហើយ។

**១កូរិថូស ១២: ៧** ហើយទ្រង់ប្រទានឲ្យព្រះវិញ្ញាណសំដែងមកក្នុងគ្រប់គ្នា ដើម្បីឲ្យបានកើតផល ។

**១កូរិថូស ១២: ៨-១១** ដ្បិតទ្រង់ប្រទានឲ្យម្នាក់មានពាក្យសំដីនៃប្រាជ្ញាវាងវៃ ដោយសារព្រះវិញ្ញាណ ឲ្យម្នាក់ទៀតមានពាក្យសំដីនៃចំណេះចេះស្ទាត់ តាមព្រះវិញ្ញាណដដែល ៩ ហើយឲ្យម្នាក់ផ្សេងទៀតមានសេចក្តីជំនឿ ដោយនូវព្រះវិញ្ញាណដដែល ឲ្យមួយទៀតបានអស់ទាំងអំណោយទាន នឹងអាចប្រោសឲ្យជា ដោយនូវព្រះវិញ្ញាណដដែល ១០ ឲ្យមួយទៀតបានសំដែងការឫទ្ធិបារមី និងឲ្យមួយទៀតចេះអធិប្បាយ ឲ្យមួយទៀតសង្កេតស្គាល់អស់ទាំងវិញ្ញាណ ឲ្យមួយទៀតចេះនិយាយភាសាដទៃទៀតៗ ហើយឲ្យមួយទៀតចេះបកប្រែភាសាដទៃ ១១ តែគឺជាព្រះវិញ្ញាណតែមួយដដែលនោះឯង ដែលធ្វើគ្រប់ការទាំងនោះ ទាំងចែកដល់គ្រប់គ្នាដោយមុខៗ ផង តាមដែលទ្រង់សព្វព្រះហឫទ័យ។

**២ធីម៉ូថេ ១: ១៤** ចូររក្សាបញ្ញើល្អដែលផ្ញើទុកនឹងអ្នក ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលសណ្ឋិតនៅក្នុងយើង។

**បកប្រែដោយៈ ONE -2 -ONE CAMBODIA**
**អាស័យដ្ឋានៈ # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**
**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
www.One-2-One world.org
www.derekprince.co.nz PC13